# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧១ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារសម្រាប់សម្របសម្រួលនិងដោះស្រាយ សំណូមពររបស់អាជីវករនៅផ្សារលើ ក្រុងព្រះសីហនុ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

### សម្រេច

**ប្រការ១:** _ត្រូវបានបង្កើតក្រុមការងារសំរាប់សំរបសំរួល និងដោះស្រាយសំណូមពររបស់អាជីវករនៅផ្សារលើ ក្រុងព្រះសីហនុ ហៅកាត់ថា "ក្រុមការងារ" ។

**ប្រការ២:** _ក្រុមការងារមានសមាសភាពដូចខាងក្រោម ៖

- ឯកឧត្តម នីយ រឿន អគ្គលេខាធិការរងរាជរដ្ឋាភិបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាងសាលាក្រុងព្រះសីហនុ សមាជិក
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

**ប្រការ៣:** ក្រុមការងារនេះមានភារកិច្ចដូចតទៅ ៖

- ពិនិត្យសំណូមពរជាក់ស្តែងរបស់អាជីវករផ្សារលើ

_ប្រមូលពត៌មាន វិភាគពត៌មាន និងវាយតំលៃអំពីស្ថានការណ៍ដែលកើតឡើងទាក់ទងនឹងលក្ខខ័ណ្ឌនៃការធ្វើ អាជីវកម្មផ្សារចាស់(ផ្សារលើ) និងផ្សារថ្មី (មជ្ឈមណ្ឌលពាណិជ្ជកម្មរបស់ក្រុមហ៊ុន វ៉ាយ ជូ ស្ថាបនា អភិវឌ្ឍន៍ ហ្វូលឌីង ចំកាត់)

_រិះរកវិធីសាស្ត្រ មធ្យោបាយ និងវិធានការដែលធានាអោយមានសុវត្ថភាព ប្រក្រតីភាព ស្ថេរភាព អាជីវកម្ម និងការទទួលផលដែលអាចទទួលយកបានដូចៗគ្នារវាងភាគីទាំងឡាយដែលពាក់ព័ន្ធ

_ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលអោយបានទាន់ពេល ដើម្បីពិនិត្យដោះស្រាយនូវរាល់ករណីដែលបានកើតឡើង

**ប្រការ៤:** _សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

**ប្រការ៥:** _រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី និងឯកឧត្តមអស់លោកដែលមានឈ្មោះក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

<u>ចម្លងជូន:</u>

_ក្រសួងព្រះបរមរាជវាំង

_អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

_អគ្គលេខាធិការដ្ឋានរដ្ឋសភា

"ដើម្បីជូនជ្រាប"

_ដូចប្រការ ៥ "ដើម្បីអនុវត្ត"

_ឯកសារ_កាលប្បវត្តិ